01221967

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 05 / 04 / 2016
ម៉ោង (Time/Heure): 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Sann Rada



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

**ជូនចំពោះ÷** ឧត្តមសេនីយ៍ទោ ឡោ សុឡេង អនុប្រធានផ្នែកសន្តិសុខប្រចាំ អ.វ.ត.ក — ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៦

**ពី÷** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន÷** ឯ.ឧ ក្រាញ់ តូនី ប្រធានស្តីទីនៃការិយាល័យរដ្ឋបាល អ.វ.ត.ក លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង, ភាគីទាំងអស់ក្នុងសំណុំរឿង ០០២

**កម្មវត្ថុ÷** សំណើសុំរបាយការណ៍ពាក់ព័ន្ធនឹងសាក្សីដែលមានរហស្សនាម 2-TCW-827

១. អង្គជំនុំជម្រះសាលាដំបូងបានព្យាយាមកោះហៅសាក្សី 2-TCW-827 ឲ្យមកផ្តល់សក្ខីកម្ម ដោយគាត់ត្រូវបានកំណត់ឲ្យមកផ្តល់សក្ខីកម្ម ពាក់ព័ន្ធនឹងអង្គហេតុស្តីពីការប្រព្រឹត្តិចំពោះជនជាតិចាម នៅក្នុងដំណើរការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ចាប់តាំងពីខែ កញ្ញា ឆ្នាំ ២០១៥ មក។ សាក្សីរូបនេះបានបដិសេធមិនទទួលយកដីកាកោះម្តងហើយម្តងទៀត។ ទោះបីជាគាត់បានអះអាងថាមានសុខភាពទន់ខ្សោយ ដែលជាមូលហេតុមួយក្នុងចំណោមមូលហេតុនានា ដែលគាត់យកមកសំអាងដើម្បីបដិសេធមិនមកផ្តល់សក្ខីកម្មនៅចំពោះមុខ អ.វ.ត.ក ក៏ដោយ ក៏សាក្សីរូបនេះបានបដិសេធមិនព្រមឲ្យមានការវាយតម្លៃផ្នែកវេជ្ជសាស្ត្រនោះដែរ។ នៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ អង្គភាពគាំពារសាក្សី និងអ្នកជំនាញបានធ្វើការព្យាយាមជាលើកចុងក្រោយ ក្នុងផ្តល់ឱកាសសម្រាប់ធ្វើការវាយតម្លៃផ្នែកវេជ្ជសាស្ត្រ និងសេវានានាដែលមាន ដើម្បីជួយគាត់ក្នុងអំឡុងពេលផ្តល់សក្ខីកម្ម តែសាក្សីរូបនេះបានបដិសេធ។ ក្នុងឱកាសនេះ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក៏បានធ្វើ

ឲ្យប្រាកដថា សាក្សីបានដឹងយ៉ាងច្បាស់ថា មាត្រា ៣១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានអនុញ្ញាតឲ្យតុលាការប្រើប្រាស់កម្លាំងសាធារណៈ ដើម្បីបង្ខំគាត់ឲ្យមកផ្តល់សក្ខីកម្ម ហើយសាក្សីនេះក៏បានបញ្ជាក់ដោយផ្ទាល់មាត់ថា គាត់បានដឹងពីចំណុចនេះដែរ។

២. នៅថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៦ បន្ទាប់ពីបានប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ក្នុងការបញ្ចុះបញ្ចូលឲ្យសាក្សីមកផ្តល់សក្ខីកម្មហើយនោះ មន្ត្រីច្បាប់ម្នាក់ពីអង្គជំនុំជម្រះសាលាដំបូងបានស្នើតាមរយៈសារអេឡិចត្រូនិកមួយ សុំជួបជាមួយមន្ត្រីនគរបាលយុត្តិធម៌ប្រចាំ អ.វ.ត.ក គឺឧត្តមសេនីយទោ ឡោ សុឡេង។ នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦ ក្រោយពីមិនបានទទួលការឆ្លើយតបទៅនឹងសារអេឡិចត្រូនិកនោះ និងក្រោយពីបានទទួលដំណឹងថា លោក ឡោ សុឡេង នឹងត្រូវធ្វើដំណើរទៅប្រទេសចិននាពេលឆាប់ៗនោះ មន្ត្រីច្បាប់ម្នាក់នៃអង្គជំនុំជម្រះសាលាដំបូងបានទាក់ទងលោក ឡោ សុឡេង តាមទូរស័ព្ទ ដើម្បីពិភាក្សាពីការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួនសាក្សីមកកាន់ អ.វ.ត.ក ដោយប្រើប្រាស់កងកម្លាំងសាធារណៈ។

៣. នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៦ នៅពេលដែលអង្គជំនុំជម្រះរៀបចំចេញដីកាបង្គាប់ទៅមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីនាំខ្លួនសាក្សី 2-TCW-827 មកកាន់តុលាការ ដោយប្រើប្រាស់កម្លាំងនោះ លោក ឡោ សុឡេង បានជូនដំណឹងមកប្រធានអង្គជំនុំជម្រះសាលាដំបូងថា សាក្សី 2-TCW-827 បានទទួលយកដីកានោះ និងយល់ព្រមមកផ្តល់សក្ខីកម្មនៅចំពោះមុខ អ.វ.ត.ក។ ដោយផ្អែកលើការលើកឡើងនេះ អង្គជំនុំជម្រះបានផ្អាកការចេញដីកានោះ និងបានកំណត់ពេលស្តាប់សក្ខីកម្មសាក្សី 2-TCW-827 នៅថ្ងៃ ចន្ទ ទី ០៤ ខែ មេសា ឆ្នាំ ២០១៦។

៤. នៅថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៦ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ បានជូនដំណឹងមកអង្គជំនុំជម្រះថា ខ្លួនបានទទួលព័ត៌មានពី លោក ឡោ សុឡេង ថា សាក្សី 2-TCW-827 បានផ្លាស់ប្តូរចិត្ត ហើយនឹងមិនមកផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការទេ។ នៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ សាក្សីរូបនេះ ខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក ដោយមិនផ្តល់មូលហេតុអ្វីទាំងអស់។

៥. អាស្រ័យហេតុនេះ អង្គជំនុំជម្រះស្នើឲ្យលោក ឡោ សុឡេង ផ្តល់របាយការណ៍មួយច្បាប់ ដែលរៀបរាប់លម្អិតអំពីការទាក់ទងទាំងអស់ជាមួយសាក្សី 2-TCW-827 ជាលក្ខណៈផ្ទាល់ខ្លួនក្តី ឬតាមរយៈបុគ្គលផ្សេងទៀតក្តី ចាប់ពីថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦ មកទល់នឹងពេលនេះ មកអង្គជំនុំជម្រះ។ របាយការណ៍នេះនឹងត្រូវបញ្ចូលព័ត៌មានទាំងអស់ពាក់ព័ន្ធនឹងការបដិសេធរបស់សាក្សីមិនផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ រួមទាំងមូលហេតុជាក់លាក់នៃការបដិសេធនោះផង។

៦. អង្គជំនុំជម្រះស្នើឲ្យផ្តល់របាយការណ៍នេះយ៉ាងយូរត្រឹមវេលាម៉ោង ១៥ និង ៣០ នាទី ថ្ងៃអង្គារ ទី ០៥ ខែ មេសា ឆ្នាំ ២០១៦។